**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៣៦ **សាលាឧទ្ធរណ៍ព្រះរាជាណាចក្រខ្មែរ**

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ **តុលាការកំពូល**

**សាលដីកា**

លេខៈ ១២ បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥

ចុះថ្ងៃទី១៦ខែមីនាឆ្នាំ២០០៥ ដោយមានសមាសភាព ដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ប្រាក់ គីមសាន ជាចៅក្រម

៥- លោក ប៉ែន សារឿន ជាចៅក្រម របាយការណ៍

**ក្រឡាបញ្ជី**

លោក សុខ ប៊ុនសង

**តំណាងមហាអយ្យការ**

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧២"ង" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៣៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

**<u>ចោទ:</u>** ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤-១១-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទ:

១-ឈ្មោះ ខាន់ នែម (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ យោធានត្រៃយោង កើតនៅភូមិ-ឃុំ-ស្រុកឆ្លូង ខេត្តក្រចេះ ទីលំនៅមុនពេលចាប់ខ្លួននៅក្នុងបន្ទាយកងពលលេខ៩១១ ។ ឪពុកឈ្មោះឃី លេង (ស) ម្តាយឈ្មោះកុល កង (រ) ប្រពន្ធឈ្មោះស្រី មុំ មានកូន ០១នាក់ ។ នៅក្នុងឃុំ ។

២-ឈ្មោះ ប៊ុន វីរៈ ហៅអន សាក៉ា (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរយោធាន៍ត្រយោង កើតនៅស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅមុនពេលចាប់ខ្លួននៅក្នុងបន្ទាយកងពលលេខ២១១ ។ ឪពុកឈ្មោះមី ប៊ុន (ស) ម្តាយឈ្មោះតូច ស៊ួន (រ) ប្រពន្ធឈ្មោះម៉ែន សុផានី ទោស ពីមុនគ្មាន "ឃុំខ្លួន" ។

-មានមេធាវីលោកខៀវ សុផល និងលោក សៅ នឿន

៣-ឈ្មោះ គន់ ម៉ុន ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរកងរាជអាវុធហត្ថ កើតនៅភូមិ-ឃុំវាលវង់ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ទីលំនៅសព្វថ្ងៃទីផ្ទះលេខ៥៦៦ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឡាយ ម៉េង (ស) ម្តាយឈ្មោះគន់ ការ(រ) ប្រពន្ធឈ្មោះភឹម រដ្ឋា ទោសពីមុនគ្មាន "ក្រៅឃុំ" ។

៤-ឈ្មោះសូ ជិនឡុង ហៅ សុវណ្ណរ័ត្ន ហៅ នាង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិមហាសាំង ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃមណ្ឌល១ សង្កាត់លេខ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មុខរបរមិនពិតប្រាដក ។ ឪពុកឈ្មោះសូ ជុងហ៊ួ (រ) ម្តាយឈ្មោះកោ សុផានី ប្រពន្ធឈ្មោះង៉ូវ មីវលួង ទោសពីមុនគ្មាន "គេចខ្លួន" ។

៥-ឈ្មោះលី ហាស៊ិន ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិតៃវ៉ាន់ កាន់លិខិតឆ្លងដែនលេខ x០០៩៩៥៩៥៩ "គេចខ្លួន" ។

-ដើមបណ្តឹងរដ្ឋប្បវេណី :

១-ឈ្មោះខេង សាមីឌី ( William tay)(ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៤៧៨ $E_0$ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-គ្មានមេធាវី

២-ឈ្មោះវី លៀមតេ( William tay) (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិសិង្ហបុរី សព្វថ្ងៃស្នាក់នៅ សណ្ឋាគារហូលីដេ ។

-មានមេធាវីលោកឃិន សារ៉ាត

-អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ប្តឹងសាទុក្ខ

តាមរបាយការណ៍ចុះថ្ងៃទី០៤-១១-២០០១ របស់ការិយាល័យនគរបាល ព្រហ្មទណ្ឌក៏រិតធ្ងន់បញ្ជាក់ថា នៅម៉ោង២១h ទៅ២២h នាថ្ងៃទី០៣-១១-២០០១ ជនជាឃាតករទាំងពីរនាក់បានចូលមកក្នុងបរិវេណសណ្ឋានគារតែម្តង ដល់ម៉ោងប្រហែល៣ទៀបភ្លឺថ្ងៃទី០៤-១១-២០០១ ជនទាំងពីរនេះមកទៀត ម្នាក់អង្គុយលើម៉ូតូលើចិញ្ចើមថ្នល់ក្រោមដើមដូងមុខសណ្ឋាគារ និងម្នាក់ចូលក្នុងបរិវេណសណ្ឋាគា អង្គុយចាំពីមុខមាត់ទ្វារចេញ ដល់វេលាម៉ោងខាងលើលោក វី លៀមតេ ចេញពីសណ្ឋាគារជាមួយអ្នកការពារពីរនាក់ និងស្ត្រី១នាក់ ត្រូវបានឃាតករបាញ់ប្រហារចំនួន៥ ទៅ៦គ្រាប់បណ្តាលឱ្យត្រូវលោកវី លៀមតេ ,ប៊ូ សារិទ្ធិ និងលោក

ខេង ហមឌី ឃាតករ រត់ចេញទៅក្រៅឡើងជិះម៉ូតូគ្នាវា ដែលចាំនៅខាងក្រៅទៅបាត់ ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការក្រុងភ្នំពេញ បានសំរេចថា: ចោទប្រកាន់លើឈ្មោះ ខាន់ ឆែម ភេទប្រុស អាយុ៣១ឆ្នាំ .ប៊ុន វិរៈ ហៅអន សារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ. គន់ ម៉ុន ភេទប្រុស អាយុ៣១ឆ្នាំ .លី ហានសិន ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះសូម ជិនឡុង ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ ឃាសកម្មគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ បទល្មើស ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៦ "ង" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-អោយរួចផុតពីបទចោទប្រកាន់លើឈ្មោះគន់ ម៉ុន ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិវាលវង់ ឃុំវាលវង់ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៦៦ សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ មុខរបរកងរាជអាវុធហត្ថ ។ ឪពុកឈ្មោះឡាយ ម៉េង (ស) ម្តាយឈ្មោះគន់ ការ៉(រ) ប្រពន្ធឈ្មោះភឹម វដ្តា ទោសពីមុនគ្មាន ពីបទ: ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤-១១-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចមានកំណត់ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៣០៨ ចុះថ្ងៃទី៣០-០១-២០០២ និងដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ៩៩៥ ត.ព្រ ចុះថ្ងៃទី៣១-០១-២០០២ តទៅ ។

២-ផ្តន្ទាទោសជនជាប់ចោទ:

ក.ឈ្មោះខាន់ ឆែម ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃស្នាក់នៅបន្ទាយកងពលលេខ៩១១ មុខរបរយោធិនឆ័ត្រយោង ឪពុកឈ្មោះឃី លេង (ស) ម្តាយឈ្មោះកុល កង (រ) ប្រពន្ធឈ្មោះស្រី មុំ មានកូន ០១នាក់ ទោសពីមុនគ្មានដាក់ពន្ធនាគារ រយៈពេល ១៤ឆ្នាំ (ដប់បួនឆ្នាំ) តែទោសនេះ ត្រូវយកទៅអនុវត្តក្នុងពន្ធធាគារ កំណត់រយៈពេល១០ឆ្នាំ (ដប់ឆ្នាំ) ចាប់គិតពីថ្ងៃឃុំខ្លួនទី(១៥-១១-២០០១) តទៅ រីឯទោសដែលនៅសល់ត្រូវព្យួរក្នុងក៏រិតសាកល្បង៥ឆ្នាំ ចាប់គិតពីថ្ងៃអនុវត្តទោសក្នុងពន្ធនាគារចប់ជាស្ថាពរពីបទ: ឃាដកម្មគិតទុកជាមុន .និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣១ .៥៤.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ-ឈ្មោះលី ហាស៊ិន ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិចិនតៃវ៉ាន់ កាន់លិខិតឆ្លងដែនលេខ x០០៩៥៥៩៥៩ "គេចខ្លួន" ដាក់ពន្ធនាគារកំណត់រយៈពេល១៤ឆ្នាំ (ដប់បួនឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានតទៅពីបទ: ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

គ-ឈ្មោះ សូ ជិនឡុង ហៅ សុវណ្ណរ័ត្ន ហៅ នាង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅ

ភូមិ មហាសាំង ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃមណ្ឌល១ សង្កាត់លេខ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មុខរបរមិនពិតប្រាដក ។ ឪពុកឈ្មោះសូ ជុងហ៊ូ ( រ ) ម្ដាយឈ្មោះកោ សុផានី ប្រពន្ធឈ្មោះ ង៉ូវ មីវលួង ទោសពីមុនគ្មាន"គេចខ្លួនបាត់" ដាក់ពន្ធនាគារកំណត់រយៈពេល១៣ឆ្នាំ( ដប់បីឆ្នាំ) តែទោសនេះត្រូវយកទៅអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល១០ឆ្នាំ ( ដប់ឆ្នាំ) ចាប់គិតពីថ្ងៃចាប់ខ្លួនបានតទៅ រីឯទោសដែលនៅសល់ត្រូវព្យួរក្នុងកំរិតសាកល្បង៥ឆ្នាំ ចាប់គិតពីថ្ងៃអនុវត្តទោសពន្ធនាគារចប់ជាស្ថាពរ ពីបទៈឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣១.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ឃ-ឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា ( ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរយោធានត្រយោង កើតនៅស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅមុនពេលចាប់ខ្លួននៅក្នុងបន្ទាយកងពលលេខ២១១ ។ ឪពុកឈ្មោះមី ប៊ុន ( ស ) ម្ដាយឈ្មោះតូច ស៊ួន ( រ ) ប្រពន្ធឈ្មោះម៉ែន សុធានី ទោស ពីមុនគ្មាន ដាក់ពន្ធនាគារកំណត់រយៈពេល១០ឆ្នាំ ( ដប់ឆ្នាំ) តែទោសនេះ ត្រូវយកទៅអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល០៨ឆ្នាំ( ប្រាំបីឆ្នាំ) ចាប់គិតពីថ្ងៃឃុំខ្លួនទី ( ១៥-១១-២០០១ ) រីឯទោសដែលនៅសល់ត្រូវព្យួរ ក្នុងកំរិតសាកល្បង០៥ឆ្នាំ ចាប់គិតពីថ្ងៃអនុវត្តទោសក្នុងពន្ធនាគារចប់ជាស្ថាពរ ពីបទៈឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣១.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គាប់អោយជនជាប់ចោទ :

ក-ឈ្មោះ ខាន់ ឆែម.ឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា.ឈ្មោះលី ហាស៊ីន.ឈ្មោះសូ ជិនឡុង ហៅសូ វណ្ណរ័ត្ន ហៅនាង មានកាតព្វកិច្ចរួមគ្នាសងថ្លៃថ្នាំព្យាបាល និងជំងឺចិត្តទៅជនរងគ្រោះឈ្មោះវី លៀមតេ ចំនួន១២.០០០.០០០រៀល( ដប់ពីរលានរៀល) ការទាមទារលើពីនេះត្រូវបដិសេធចោល ។

ករណីជនជាប់ចោទទាំង៤នាក់ ខាងលើម្លេះមិនព្រមអនុវត្តតាមការកំណត់ខាងលើទេនោះ ត្រូវចាប់ដាក់គុកបង្ខំរូបរាងកាយ ទារប្រាក់ធមទណ្ឌក្នុងម្នាក់១ ២ឆ្នាំ តាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ។

ខ-រក្សាសិទ្ធិឱ្យជនរងគ្រោះឈ្មោះខេង សាម៉ុឌី ដើមបណ្ដឹងរដ្ឋប្បវេណី ឬសិទ្ធិវិន្តតំណាងជនរងគ្រោះឈ្មោះបូ សារិទ្ធិ ប្ដឹងទាមទារសំណងផ្សេងៗ និងជំងឺចិត្តពីជនជាប់ចោទឈ្មោះខាន់ ឆែម.ឈ្មោះប៊ុនវីរៈ ហៅអន សារ៉ា.ឈ្មោះលី ហាស៊ិន.ឈ្មោះសូ ជិនឡុង ហៅសូ វណ្ណរ័ត្ន ហៅនាង នៅតុលាការរដ្ឋប្បវេណីនាពេលក្រោយ ។

៤-វត្ថុតាងៈ

ក-ទូរស័ព្ទដៃម៉ាក អេរីសាន់ ពណ៌ខៀវ ប្រភេទR ៣១០SC លេខ០១៦ ៨៧៥ ៩០០ ជាកម្មសិទ្ធិរបស់ឈ្មោះខាន់ ឆែម ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

ខ-ទូរស័ព្ទដៃម៉ាក អេរីសាន់ GF៧៦៨ លេខ ០១៦ ៨៣៣ ៣៣២ ជាកម្មសិទ្ធិរបស់ឈ្មោះ គន់ ម៉ុន ត្រូវប្រគល់ឱ្យទៅឈ្មោះគន់ ម៉ុន ប្រើប្រាស់ដូចដើមវិញ ចាប់ពីថ្ងៃនេះតទៅ ។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះ ខាន់ ឆែម គន់ ម៉ុន.ប៊ុន វីរៈ កំបាំងមុខជនជាប់ចោទឈ្មោះ លី ហានស៊ិន . សូ ជិនឡុង កំបាំងមុខជនរងគ្រោះ សំរេចបើផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងសាលក្រមនេះ សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃផុតកំណត់រយៈពេលប្តឹងទាស់តទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ២២"ង" ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះខាន់ ឆែម និងបណ្តឹងឧទ្ធរណ៍លេខ២១"ង"ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះប៊ុន វីរៈ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៦ "ង" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ បានសំរេចថា:

+តំកល់សាលក្រមលេខ២៦ "ង" ចុះថ្ងៃទី០៥-០៤-២០០២ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ តែបដិសេធចោលទាំងស្រុង នូវចំណុច ទី២ "ឃ" នៃសេចក្តីសំរេចរបស់សាលក្រមនេះ ។

+អោយឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា រួចផុតពីបទចោទ ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ ចាប់ពីពេលនេះតទៅ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧២ "ង" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-៥-២០០២ របស់ឈ្មោះខាន់ ឆែម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៥-២០០២ របស់ឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៦ "ង " ចុះថ្ងៃទី០៥-០៤-២០០២ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី២"ក" និង"ឃ" និង៣"ក "កថាខ័ណ្ឌទី១ ត្រូវកែប្រែជាថ្មី :

៣-១ : ផ្តន្ទាទោសឈ្មោះខាន់ ឆែម ភេទប្រុស អាយុ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ ចាប់គិតពីថ្ងៃទី១៥-១១-២០០១ ពីបទៈឃាដកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ តាមមាត្រា៣១ និង៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-៩-២០០១ ។

៣-២: អោយឈ្មោះ ប៊ុន វីរៈ ហៅអន សារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ រួចខ្លួន ពីបទចោទ បទឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី០៤-១១-២០០១ ។

៣-៣: បង្គាប់អោយជនជាប់ចោទឈ្មោះខាន់ ឆែម.លី ហានស៊ិន.សូ ជិនឡុង ហៅ សុវណ្ណរ័ត្ន ហៅនាង រួបរួមគ្នាសងសំណងរដ្ឋប្បវេណី ថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តសរុបចំនួន១២.០០០.០០០រ (ដប់ពីរលានរៀល) ទៅអោយឈ្មោះវី លៀមគេ ។ ការទាមទារលើសពីនេះ បដិសេធចោល ។

-ចំណុចផ្សេងពីនេះនៃសាលក្រម រក្សាទុកជាបានការដដែល

៤-សាលដីកានេះជំនុំជំរះ នៅថ្ងៃទី០៩-១០-២០០៣ ចំពោះមុខឈ្មោះ ខាន់ ឆែម.ប៊ុន វីរៈ ហៅ អន សារ៉ា ចំពោះមុខមេធាវីឈ្មោះតៃ ចំណាន កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសារធារណៈ នៅថ្ងៃទី១៣-១០-២០០៣ កំបាំងមុខជនជាប់ចោទឈ្មោះខាន់ ឆែម.ប៊ុន វីរៈ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ វី លៀមគេ ចំពោះមុខមេធាវីឈ្មោះ តៃ ចំណាន ។

បានឃើញបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ របស់អគ្គព្រះរាជអាជ្ញា និង បណ្តឹងសាទុក្ខលេខ១៤២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះខាន់ ឆែម ប្តឹងមិនសុខចិត្តនឹង សាលដីកា ព្រហ្មទណ្ឌលេខ៧២ "ង" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេច ទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

បានឃើញសារណាការពារ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះ ខាន់ ឆែម

បានឃើញសារណាតប ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា

បានឃើញឈ្មោះ ខេង សាមុីឌី និងលោកមេធាវី យិន សារ៉ាត ទទួលលិខិតបង្គាប់អោយធ្វើសារណា របស់តុលាការកំពូល នៅថ្ងៃទី២៦-០៧-២០០៤ និងថ្ងៃទី០៩-០៨-២០០៤ រួចហើយ តែឈ្មោះនេះមិនព្រម ធ្វើសារណាតប ជូនមកតុលាការកំពូលវិញទេ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងតំណាងមហាអយ្យការ អមតុលាការកំពូលថា: សាលាឧទ្ធរណ៍ បានឱ្យឈ្មោះប៊ុន វីរៈ រួចផុតពីបទចោទដោយព្រះរាជអាជ្ញា មិនធ្វើការចោទប្រកាន់នោះ គឺជាការយល់ខុស តាមការពិត ឈ្មោះប៊ុន វីរៈនេះបានឧបជនជាប់ចោទ និងបានឃើញសកម្មភាពជនជាប់ចោទគ្រប់តំណាក់កាល ដូច្នេះ ប៊ុន វីរៈ នេះ ជាអ្នកសំរួលដល់ជនជាប់ចោទយ៉ាងពិតប្រាកដ ហើយអយ្យការថ្នាក់ក្រោមក៏បានចោទ ប្រកាន់រួចហើយដែរ ចំណែកការព្យួរទោសក្នុងបទឧក្រិដ្ឋមិនមានទ ដូច្នេះសូមតុលាការពិចារណា និង សូម បង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ ដោយបដិសេធសាលដីកាព្រហ្មទណ្ឌនេះចោលជាអសារបង់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះខាន់ ឆែម (ម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា :

+ ខ្ញុំមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទេ

+ ខ្ញុំសូមឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសឱ្យខ្ញុំផង

+ ខ្ញុំគ្មានទំនាក់ទំនងអ្វីមួយឈ្មោះ វី លៀមតេ ទេ

+ ពេលដើរចូលទៅ ហ្វូលីដេ គឺមានបំណងទៅរកស្រី មិនមែនរកជនរងគ្រោះទេ

+ ពេលដើរ គឺជនរងគ្រោះបានដើរប៉ះគ្នាហើយ ក៏មានទំនាស់ជាមួយអង្គរក្សជនរងគ្រោះ ក៏ធ្វើឱ្យមានការបាញ់គ្នា ។

+ លោក លី ហាស៊ិន បានឱ្យខ្ញុំព្រមានទៅនឹងលោក វី លៀមតេ

+ ខ្ញុំបានទទួលលុយគាត់ពីអ្នកបកប្រែម្នាក់របស់គាត់ដែលមិនចំណាំមុខចំនួន៥០០ដុល្លាអាមេរិក ដែលខ្ញុំគិតថា ខ្ញុំនឹងបោកយកលុយនោះចាយតែប៉ុណ្ណោះ ។

+ នៅពេលកើតហេតុនោះ គឺខ្ញុំមិនបានទៅចាំជនរងគ្រោះទេ តែពេលខ្ញុំចូលទៅចៃដន្យជួបគ្នាតែម្តង ដូច្នេះ សូមបន្ធូរបន្ថយទោសខ្ញុំផង ។

បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា (ចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថាៈ

+ ខ្ញុំមិនបានដឹងសមត្ថភាពរបស់ ខាន់ ឆែម ទេ

+ ខ្ញុំគ្រាន់តែ គេរកខ្ចីលុយវា សំរេច ជិះម៉ូតូឌុបពីបេនតាក់ស៊ីទៅកងពលតែប៉ុណ្ណោះ ព្រោះខ្ញុំជិះតាក់ស៊ីមកពីស្រុកអស់លុយរលីង

+ ពេល ខាន់ ឆែម មកជួបខ្ញុំក៏បបួលខ្ញុំដើរស៊ីផឹកសិនចាំទៅកន្លែងទាំងអស់គ្នា ពេលនោះខ្ញុំក៏ ទៅជាមួយ ខាន់ ឆែម ដោយខ្ញុំជាអ្នកឌុប លុះដើរស៊ីផឹកកាន់តែយប់ជ្រៅ ទើបបបួលគ្នាទៅរកស្រី នៅ ហ្វូ លីដេ ។

+ នៅហ្វូ លីដេ ខាន់ ឆែម ជាអ្នកដើរចូល ដោយខ្ញុំជាអ្នកចាំនៅខាងក្រៅដោយរវល់មើលពួកម៉ូតូឌុបលែងបៀរ មិនដឹងខាងក្នុងមានរហេតុការណ៍អ្វីកើតឡើងទេ ព្រោះពេលនោះ ក៏មានសំលេងធុងបាសឡានក៏បានបន្លឺនៅក្បែរខ្ញុំដែរធ្វើខ្ញុំមិនឮអ្វីទាំងអស់ ឬមើលឃើញអ្វីទេដែរ ព្រោះពីកន្លែងខ្ញុំឈរទៅក្នុង ហ្វូ លីដេ ត្រូវបាំងដោយរបងខ្ពស់ៗ មិនដូចអគ្គសាលាឧទ្ធរណ៍ចោទខ្ញុំនោះទេ ។

+ ពេលខាន់ ឆែម ចេញមកវិញក៏អោយខ្ញុំឌុបទៅមាត់ទន្លេបើកដោយយឺតៗ ព្រោះទាំងខ្ញុំទាំងខាន់ ឆែម ស្រវឹងទាំងអស់គ្នា និង ខាន់ ឆែម បានប្រាប់ខ្ញុំថា នៅមាត់ទន្លេសំបូរមនុស្សប្រុសស្រីញៀវគ្នាណាស់ ដូច្នេះ ខ្ញុំសូមឱ្យតុលាការដោះលែងខ្ញុំផង ។

បានស្តាប់ចម្លើយអះអាងបន្ថែមរបស់ឈ្មោះខាន់ ឆែម (ម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ពេលខ្ញុំទៅយកលុយ គឺខ្ញុំទៅយកតែម្នាក់ឯង ។ ពេលខ្ញុំទៅបោះកាំភ្លើងចោលក្នុងទន្លេ ខ្ញុំក៏មិនដឹងថា ប៊ុន វីរៈ ដឹង ឬ មិនដឹងទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក សៅ ឿន ការពារជនជាប់ចោទ នៅពេលជំនុំជំរះ ថាៈ

តាមអង្គហេតុ និងអង្គច្បាប់ឃើញថា កូនក្តីខ្ញុំទាំងអស់មិនមានធាតុផ្សំណាមួយចូលទៅធាតុផ្សំទាំងបីរបស់បទល្មើសនោះទេ ព្រោះគ្មានគំរោងជាមុនដូចជា :

+ ប៊ុន វីរៈ មកពីស្រុកអស់លុយ ក៏តេ ទៅរកខ្ចីលុយ ខាន់ ឆែម

+ ពេល ខាន់ ឆែម មកជួបក៏បបួលដើរលេងសិន លុះការដើរលេងពីកន្លែងមួយទៅកន្លែងមួយក៏មានភាពស្រវឹង ហើយក៏បបួលគ្នាទៅរកស្រីនៅ ហ្វូ លីដេ

+ ពេលទៅដល់ហ្វូ លីដេ ប៊ុន វីរៈ នៅខាងក្រៅខាន់ ឆែមចូលទៅក្នុងក៏ប្រទះជាមួយជនរងគ្រោះក៏ផ្ទុះអាវុធជាមួយអង្គរក្សជនរងគ្រោះ ហើយវីរៈ មិនបាន ឮនឹងឃើញអ្វីទាំងអស់

+ ពេលទៅមាត់ទ្វេ ក៏ប៊ុន វីរៈ មិនដឹងអ្វីដែរ គ្រាន់តែខ្លួនទៅទីនោះដឹងថា មានគេសាងសងគ្នា តែប៉ុណ្ណោះ ។ ដូច្នេះ កូនក្តីខ្ញុំទាំងពីមិនមានគំរោងក្នុងការធ្វើឃាដជនរងគ្រោះទេ ។

+ ម្យ៉ាងទៀត ការចាប់ខ្លួនកូនក្តីខ្ញុំមិនត្រឹមត្រូវទៅតាមនីតិវិធីឡើយ គឺពេលចាប់ខ្លួនមិនមែនបទល្មើសជាក់ស្តែង គ្មានដីកាចាប់ខ្លួន ។

ដូច្នេះ សូមតម្កល់សាលដីកាសាលឧទ្ធរណ៍ គ្រាន់តែកែប្រែត្រង់ចំណុចខាន់ ឆែម ដើម្បីឱ្យបានបន្ធូបន្ថយទោស និងតម្កល់ត្រង់ចំណុច ប៊ុន វីរៈ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ខៀវ សុផល ការពារជនជាប់ចោទ នៅពេលជំនុំជំរះ ថាៈ បើពិនិត្យតាមដំណើររឿងកូនក្តីខ្ញុំ គ្មានបំណងទៅប្រព្រឹត្តដូចការចោទប្រកាន់របស់អយ្យការ តុលាការថ្នាក់ក្រោមឡើយ ដូចជា :

+ ពេល ប៊ុន វិរៈ ខ្ចីលុយខាន់ ឆែម ហើយខាន់ ឆែម ជួបក៏បបួលគ្នាទៅស៊ីផឹក គឺអ្នកទាំងពីរគ្មានគំនិត គិតទុកជាមុនទេ

+ ពេលហូប ហើយកូនក្តីខ្ញុំទៅរកស្រីក៏ជួបជនរងគ្រោះ

+ វាគ្មានធាតុផ្សំណាមួយសំរាប់ធ្វើបទល្មើសទេ

+ តែវាជាហេតុមួយចៃដន្យ គឺចេតនាទៅរកស្រី មិនចេតនាទៅរកបាញ់ទេ ប៉ុន្តែពេលដើរចូលទៅ ក៏ប៉ះគ្នាជាមួយជនរងគ្រោះ និងអង្គរក្ស និងអង្គរក្សហក់មកចាប់ខាន់ ឆែម វាក៏រាំកែតែម្តងទៅ ដូច្នេះពេលផ្ទុះអាវុធនេះ ជារឿងអចេតនាទេ ។

+ ចំណែកប៊ុន វិរៈ មិនបានដឹងអ្វីទាំងអស់ គឺដឹងតែទៅហូបចុកនិងទៅរកស្រី ហើយមកដល់កន្លែង កើតហេតុ គ្នាក៏នៅចាំខាងក្រៅទៀត ។

+ ដូច្នេះ កាលបានលុយពីគេជូនោះ កូនក្តីខ្លួនគ្មានបំណងទៅបាញ់គេទេ គឺចង់បានលុយនោះទៅចាយតែប៉ុណ្ណោះ ។

+ ចម្លើយរបស់កូនក្តីខ្ញុំនៅ នគរបាល ជាចម្លើយបន្ទាល់ទេ ដែលមិនអាចយកជាការបាន

ព្រោះត្រូវគេបង្ខិតបង្ខំ គឺមានតែចម្លើយនៅអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបទេ ដែលអាចយកជាការបាន ដូច្នេះ សូមមេត្តា សំរេចឱ្យប៊ុន វីរៈ រួចខ្លួន និងកែប្រែ បទល្មើសរបស់ខាន់ ឆែម ពីមនុស្សឃាដចេតនាមកអចេតនាវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក យិន សាវ៉ាត ការពារជនរងគ្រោះ នៅពេលជំនុំជំរះ ថាៈ នៅថ្ងៃទី០៤-១១-២០០១ វេលាម៉ោង៥ ទាបភ្លឺ កូនក្តីខ្ញុំបានដើរចេញពីក្តុងហ្វូ លីដេ តំរងទៅរថយន្ត ស្រាប់តែឈ្មោះខាន ឆែម បាញ់ឱ្យត្រូវរបួស និងមានអ្នកស្លាប់ទៀតផង គឺបានបាញ់ជាច្រើនគ្រាប់មកលើពួកកូនក្តីខ្ញុំ វាជាចេតនាព្រោះនៅពេលសវនាការនេះ ខាន់ ឆែម ខ្លួនឯងក៏បានឆ្លើយសារភាពថា ខ្លួនបានទទួលលុយ ពីអ្នកជួលឱ្យបាញ់កូនក្តីខ្ញុំចំនួន៥០០ដុល្លាអាមេរិក រួចទៅហើយ នេះមានគំរោងរួចទៅហើយ ។

បានស្តាប់ចម្លើយអះអាងបន្ថែមរបស់ឈ្មោះប៊ុន វីរៈ (ចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថាៈ ជាចម្លើយដោះសារទេ ព្រោះខ្លួនជាអ្នកឌុបខាន់ ឆែម ផ្ទាល់ ហើយរឿងអីទៅរកស្រីនៅម៉ោង៥ភ្លឺទៅហើយ ដូច្នេះ សូមគាំទ្រទៅនឹងការ ប្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ និងសូមបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ វិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់មេធាវីលោក សៅ ឡើន ការពារជនជាប់ចោទ នៅពេលជំនុំជំរះ ថាៈ

+ ពេលទៅរកស្រីអាចទៅរកបានគ្រាប់ពេលវេលា

+ ការរងចាំ រឿងខាន់ ឆែម ធ្វើអ្វីនោះ គឺប៊ុន វីរៈ មិនបានដឹងទេ

+ ការចោទប្រកាន់ប៊ុន វីរៈ ហៅ អន សាវ៉ា គ្រាន់តែជាការចាប់ផ្តើម ដើម្បីឱ្យចៅក្រមជំនុំជំរះតែប៉ុណ្ណោះ វាគ្រាន់តែជាការសង្ស័យតាមមាត្រា៣៨ នៃច្បាប់រដ្ឋធម្មញ្ញ វាត្រូវមានប្រយោជន៍ដល់ជនជាប់ចោទ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះ ថា : វាមិនមែនរាកែ វាជាការបាញ់មនុស្សចំមុខសញ្ញាដែលគេជួលឱ្យបាញ់តែម្តង ។ ចម្លើយគ្មានសាក្សី មានតែចម្លើយរបស់ជនជាប់ចោទខ្លួនឯង មិនអាចឱ្យជឿបាន សូមតុលាការសំរេចដោយបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោល ហើយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចម្លើយជនជាប់ចោទ ឈ្មោះខាន់ ឆែម និងប៊ុន វីរៈ ហៅអន សាវ៉ា ព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៣ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ និងបណ្តឹងសាទុក្ខលេខ៦៤២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣ របស់ជនជាប់ចោទឈ្មោះ ខាន់ ឆែម ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការ ចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យឈ្មោះប៊ុន វីរៈ ហៅអន សារ៉ា រួចខ្លួនពីបទចោទ ដោយសំអាងហេតុតំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ពុំបានចោទប្រកាន់ទេ ទោះបីយល់ឃើញថា មានពិរុទ្ធភាព ហើយក៏ដោយនោះជាការ ពុំត្រឹមត្រូវទេ ពីព្រោះជនជាប់ចោទនេះ ត្រូវបានព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ ចោទប្រកាន់រួចហើយ ហើយតំណាង មហាអយ្យការ អមសាលាឧទ្ធរណ៍មានសិទ្ធិត្រឹមតែសន្និដ្ឋានប៉ុណ្ណោះ ឯការសំរេចគឺអាស្រ័យលើក្រុមប្រឹក្សាជំនុំជំរះ សាលាឧទ្ធរណ៍ជាអ្នកសំរេច ។

-យល់ឃើញថា ការដែលមេធាវីការពារជនជាប់ចោទលើកឡើង សន្និដ្ឋាននៅពេលសវនាការនេះថា ជនជាប់ចោទពុំមានចេតនាធ្វើមនុស្សឃាដដោយគិតទុកជាមុន និងពុំបានពួនស្ទាក់ទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា នៅពេលសវនាការនេះ ជនជាប់ចោទឈ្មោះ ខាន់ ឆែម បានឆ្លើយថា មានឈ្មោះលី ហាស៊ិន ជាអ្នកជួលឱ្យព្រមានជនរងគ្រោះ និងបានទទួលប្រាក់ពីអ្នកមកប្រែចំនួន៥០០ដុល្លាអាមេរិករួចហើយ ហើយតាមចម្លើយឈ្មោះគន់ មុំនបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា នៅយប់កើតហេតុ ខ្លួនបានទូរស័ព្ទប្រាប់ឈ្មោះ ខាន់ ឆែម ថា ឃើញឈ្មោះ វី លៀមតេ ចូលក្នុងហាងហូ លីដេ ។ ជាមួយគ្នានេះ ឈ្មោះ ប៊ុន វីរៈ ក៏បានឆ្លើយដែរថា បានរង់ចាំឈ្មោះខាន់ ឆែម តាំងពីម៉ោង៣ ដល់ម៉ោង៥ ភ្លឺ ទើបឮស្នូរកាំភ្លើងបាញ់ ។ ដូច្នេះមានធាតុផ្សំគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទពិតជាមានចេតនាធ្វើមនុស្សឃាដគិតទុកជាមុនប្រាកដមែន ។

-យល់ឃើញថា ជនជាប់ចោទ ឈ្មោះខាន់ ឆែម និងឈ្មោះប៊ុន វីរៈ ដែលបានឆ្លើយថា ខ្លួនគ្មានចេតនាទៅសំលាប់ជនរងគ្រោះទេ គឺគ្រាន់តែទៅរកស្រី ប៉ុន្តែបែរជាប៉ះទង្គិចគ្នាជាមួយឈ្មោះវី លៀមតេ ហើយ ក៏ផ្ទុះអាវុធដោយអចេតនា នោះពុំមានភស្តុតាងដោះបន្ទុកដូចការអះអាងនេះទេ ។

-យល់ឃើញថា សាលក្រមរបស់តុលាការក្រុងភ្នំពេញ និងសាលដីការបស់សាលាឧទ្ធរណ៍សុទ្ធតែបានជំនុំជំរះ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ពុំបានជូនដំណឹងពីសាលក្រម និងសាលដីកាកំបាំងមុខនេះដែរ ដូច្នេះតុលាការទាំងពីថ្នាក់នេះ មានកំហុសក្នុងនីតិវិធីដែលគប្បីត្រូវតែ ជូនដំណឹងដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងទាស់ ប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខ ។

-យល់ឃើញថា ជនជាប់ចោទបានបាញ់មនុស្សដល់ទៅ៣នាក់ ដែលជាបទល្មើស៣ ប៉ុន្តែតុលាការថ្នាក់ក្រោមពុំបានពិនិត្យលើការផ្តន្ទាទោសឱ្យបានសមស្របលើបទល្មើសទាំង៣នេះទេ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ វី លៀមតេ និងខេង សាម៉ឺឌី បានទទួលលិខិតបង្គាប់

សារណាហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ មានតែមេធាវីរបស់លោកស្រី លៀមតេ មកចូលរួមដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧២"ង" ចុះថ្ងៃទី១៣-០១-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះខាន់ នែម និងប៊ុន វីរៈ**

**និងមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះវី លៀមតេ កំបាំងមុខដើមបណ្តឹង**

**រដ្ឋប្បវេណីនេង សាម៉ុនី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ១៤២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះខាន់ នែម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈសាលាដីកាព្រហ្មទណ្ឌលេខ៧២"ង" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៣៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ។